H.C. BHN Sub-degree

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសេចក្តីសំរេចចិត្តលេខ ៥៥/២៨២ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០១ របស់មហាសន្និបាតអង្គការសហប្រជាជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបង្កើត ទិវាសន្តិភាពអន្តរជាតិ (International Day of Peace) នៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់យកថ្ងៃទី ២១ ខែ កញ្ញា រៀងរាល់ឆ្នាំ ដើម្បីប្រារព្ធពិធីនេះ នៅទូទាំងប្រទេស។

**មាត្រា ២ :** ទិវាសន្តិភាពអន្តរជាតិ ត្រូវបានសំរេចតាមសេចក្តីសំរេចចិត្តលេខ ៥៥/២៨២ ចុះថ្ងៃទី ០៧ កញ្ញា ២០០១ របស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ ដោយកំណត់យកការប្រារព្ធពិធី នៅថ្ងៃទី ២១ កញ្ញា រៀងរាល់ឆ្នាំ ក្នុងបំណង :

- ពង្រឹងឧត្តមគតិសន្តិភាព និង បន្ធូរបន្ថយភាពតានតឹងនិងមូលហេតុផ្សេងៗនៃវិវាទ
- បញ្ឈប់រាល់អំពើហិង្សានិងវិវាទ នៅលើពិភពលោកទាំងមូល
- ប្រារព្ធពិធីនេះ ជាទិវាអន្តរជាតិ សំរាប់គ្រប់ប្រជាពលរដ្ឋគ្រប់ប្រជាជាតិ ទូទាំងសកលលោក។

**មាត្រា ៣:** ក្នុងឱកាសប្រារព្ធទិវាសន្តិភាពអន្តរជាតិនេះ គ្រប់ក្រសួងស្ថាប័នរដ្ឋ សាលាខេត្ត-ក្រុង ស្រុក ខ័ណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ សហគ្រាសសាធារណៈនិងឯកជន អង្គការក្រៅរដ្ឋាភិបាល និង គ្រឹះស្ថានសិក្សានានា

4c

ត្រូវបំផុសមន្ត្រីរាជការ មន្ត្រីនគរបាល យោធិន និយោជិត សិស្ស និស្សិត និង ប្រជាពលរដ្ឋ អោយបានយល់ដឹង និង ចាត់ទុកថា ថ្ងៃទី ២១ ខែ កញ្ញា ជាថ្ងៃគ្មានអំពើហិង្សានិងបញ្ឈប់ការផ្ទុះអាវុធ នៅទូទាំងសកលលោក ។

**មាត្រា ៤:** ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវរៀបចំសេចក្តីណែនាំ ស្តីពីខ្លឹមសារលំអិតទាំងឡាយ សំរាប់ការប្រារព្ធពិធី " ទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា " ផ្ញើជូនគ្រប់ក្រសួងស្ថាប័ន ដូចមានចែងក្នុងមាត្រា ៣ អោយបានទូលំទូលាយ ។

**មាត្រា ៥:** គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិនិងអន្តរជាតិ ដោយមានការឧបត្ថម្ភពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវសហការជាមួយគ្រប់ក្រសួងស្ថាប័ន ដូចមានចែងក្នុង មាត្រា ៣ ដើម្បីចាត់តាំងប្រារព្ធពិធី "ទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា" អោយបានល្អប្រសើរ ដោយមានការរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយនូវខ្លឹមសារ ដូចមានបញ្ជាក់ក្នុងមាត្រា ៤ ។

**មាត្រា ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិនិងអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន និង អភិបាលខេត្ត-ក្រុង ស្រុក ខ័ណ្ឌ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ